# I - ទីស្តីការគណៈរដ្ឋមន្ត្រី

## អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ១៣ អនក្រ.បក**

**ស្តីពីការបំពេញបន្ថែមក្នុងតារាងបៀវត្ស**

**ចំពោះការប្រាក់នូវបណ្តាឋានៈថ្មីសមមូលនឹង**

**ការប្រាក់ឋានៈ នាទីចាស់របស់មន្ត្រីរាជការស៊ីវិល**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញសេចក្តីសំរេចលេខ៨៩ សសរ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៨៣ ស្តីពីប្រព័ន្ធបៀវត្ស កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ
- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩២ ស្តីពីការកែលំអ បៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

– យោងសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

**សំរេច**

**មាត្រា ១** : ត្រូវបានបំពេញបន្ថែមក្នុងតារាងកាំប្រាក់ «ក២» ដែលបាននិងកំពុងអនុវត្ត សព្វថ្ងៃនូវ បណ្ណាឋានៈនាទីថ្មីបច្ចុប្បន្នរបស់មន្ត្រីរាជការស៊ីវិល ទៅតាមមុខងារ និងកាំប្រាក់ក្នុងតារាងដូចខាងក្រោម :

| ប្រភេទ | បៀវត្ស | មុខងារចាស់ | មុខងារថ្មី |
|---|---|---|---|
| ក II.1 | ៧១.០០០៛ | –ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី | –នាយករដ្ឋមន្ត្រី |
| ក II.2 | ៦៤ ៧០០៛ | –អនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី | –ឧបនាយករដ្ឋមន្ត្រី |
| ក II.3 | ៦០.០០០៛ | –រដ្ឋមន្ត្រី | –ទេសរដ្ឋមន្ត្រី<br>–រដ្ឋមន្ត្រី និង ថ្នាក់ស្មើ |
| ក II.4.3 | ៥៧ ៦០០៛ | –ប្រធានអគ្គនាយកចំណុះគណរដ្ឋមន្ត្រី | –រដ្ឋលេខាធិការ និង ថ្នាក់ស្មើ |
| ក II.4.1<br>ក II.4.2 | ៥២.៩០០៛<br>៥៥ ៣០០៛ | –អនុរដ្ឋមន្ត្រី<br>–ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត–ក្រុង | –អនុរដ្ឋលេខាធិការ និង ថ្នាក់ស្មើ<br>–អភិបាលខេត្ត - ក្រុង |
| ក II.5.1<br>ក II.5.2 | ៤៧ ៤០០៛<br>៤៩ ៧០០៛ | –អនុប្រធានគណៈប្រជាជនបដិវត្តខេត្ត - ក្រុង | –អភិបាលរងខេត្ត–ក្រុង<br>–អគ្គនាយក អគ្គាធិការ និង ថ្នាក់ស្មើ<br>–អគ្គលេខាធិការក្រសួង ឬរដ្ឋលេខាធិការដ្ឋាន |
| ក II.6.1 | [illegible]២ ៦០០៛ | –ប្រធាននាយកដ្ឋាន | –អគ្គនាយករង អគ្គាធិការរង<br>–អគ្គលេខាធិការរងក្រសួង ឬរដ្ឋលេខាធិការដ្ឋាន<br>–អធិការ |
| ក II.6.2 | ៤៤.២០០៛ | | –នាយកខុទ្ទកាល័យក្រសួង ឬរដ្ឋលេខាធិការដ្ឋាន<br>–ទីប្រឹក្សារបស់ក្រសួង ឬរដ្ឋលេខាធិការដ្ឋាន |

| | | | |
|---|---|---|---|
| | | | -ប្រធាននាយកដ្ឋាន និង ថ្នាក់ស្មើ<br>-ជំនួយការក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន |
| ក II.7.1 | ៣៩ ០០០៛ | -អនុប្រធាននាយកដ្ឋាន<br>-ប្រធានមន្ទីរជុំវិញខេត្ត-ក្រុង | -អភិបាលខ័ណ្ឌ-ស្រុក |
| ក II.7.2 | ៤០ ៦០០៛ | -ប្រធានគណៈកម្មាធិការប្រជាជនបដិវត្ត ខ័ណ្ឌ-ស្រុក | -នាយខុទ្ទកាល័យក្រសួង- ឬ រដ្ឋលេខាធិការដ្ឋាន |

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីនៃក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ — នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខា និង ត្រា — ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** — **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ៥៣ អនក្រ.តត
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា